# មធ្យោបាយបោះឆ្នោត



## បោះឆ្នោតតាមប្រៃសណីយ៍

ស្នើសុំសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ឲ្យទាន់**ថ្ងៃទី 31 ខែឧសភា**។

ប្រគល់មកវិញតាមប្រៃសណីយ៍—ត្រូវបានបោះត្រាប្រៃសណីយ៍ នៅថ្ងៃ ឬមុន**ថ្ងៃទី 7 ខែមិថុនា** ហើយការិយល័យបោះឆ្នោតខោនធីរបស់អ្នកបានទទួលមិនហួសពី**ថ្ងៃទី 10 ខែមិថុនា** ឡើយ។

ប្រគល់មកវិញដោយផ្ទាល់មុខ—ទៅឲ្យការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬកន្លែងបោះឆ្នោតណាមួយ នៅក្នុងខោនធីរបស់អ្នក ឲ្យបានមុនម៉ោង 8:00 យប់ នៅ**ថ្ងៃទី 7 ខែមិថុនា**។




## បោះឆ្នោតដោយផ្ទាល់មុខ មុនដល់ពេល

ខោនធីខ្លះ មានផ្តល់ការបោះឆ្នោតមុនដល់ពេល សំរាប់ទីកន្លែងមួយចំនួន នៅមុនថ្ងៃបោះឆ្នោត។

សូមទាក់ទងការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ក្រែងលោគេមានផ្តល់ការបោះឆ្នោតមុនដល់ពេល។

ព័ត៌មានទំនាក់ទំនងខោនធី អាចរកឃើញនៅទំព័រ 29 ឬដោយមើលវ៉ិបសៃត៍របស់រដ្ឋលេខាធិការ នៅ: *http://www.sos.ca.gov/elections/voting-resources/county-elections-offices*។



## បោះឆ្នោតនៅកន្លែងបោះឆ្នោត នៅថ្ងៃបោះឆ្នោត

កន្លែងបោះឆ្នោត បើកនៅថ្ងៃបោះឆ្នោត: **ថ្ងៃទី 7 ខែមិថុនា ពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់។**

អាសយដ្ឋាននៃកន្លែងបោះឆ្នោតរបស់អ្នក គឺបានផ្តិតនៅទំព័រខាងក្រោយនៃកូនសៀវភៅគំរូសន្លឹកឆ្នោត ដែលមន្ត្រីបោះឆ្នោតខោនធីរបស់អ្នក បានផ្ញើទៅឲ្យអ្នក។

អ្នកក៏អាចរកកន្លែងបោះឆ្នោតរបស់អ្នកបានដែរ:

- ✆ ដោយហៅលេខ (888) 345-4917
- តាមអ៊ិនធ័រណិតនៅ *www.sos.ca.gov/elections/polling-place*
- ដោយវាយពាក្យ *Vote* ទៅលេខ GOVOTE (468683)

# ការបោះឆ្នោត ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា

ការបោះឆ្នោតជាបឋមក្នុងរដ្ឋកាលីហ្វ័រនីញ៉ា មានពីរប្រភេទខុសគ្នា។ លទ្ធផលនៃការបោះឆ្នោតជាបឋម សំរេចថាបេក្ខជនណានឹងឈរឈ្មោះ ក្នុងការបោះឆ្នោតទូទៅ ក្នុងខែវិច្ឆិកា។ ប្រភេទនៃការបោះឆ្នោតជាបឋម គឺ:

## ប្រធានាធិបតី (គណៈបក្ស-បញ្ជូរឈ្មោះ/ការិយាល័យនិន្នាការ)

- តំណែងនៅលើសន្លឹកឆ្នោត: ប្រធានាធិបតី អាមេរិក
- អ្នកណាអាចបោះឆ្នោតបាន: តែអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ជាមួយនឹងគណៈបក្សនយោបាយដូចគ្នា ជាបេក្ខជន (គណៈបក្សខ្លះអនុញ្ញាតឲ្យអ្នកបោះឆ្នោត ដែលបានចុះឈ្មោះដោយគ្មានការប្រកាន់គណៈបក្ស ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតជាបឋមរបស់គេ។ មើល *http://www.sos.ca.gov/elections/political-parties/no-party-preference* សំរាប់ព័ត៌មានបន្ថែម)។
- លទ្ធផល: បេក្ខជនដែលផ្លាស់ចូលទៅការបោះឆ្នោតទូទៅ គឺជាបេក្ខជនដែលបានបញ្ជូរឈ្មោះដោយគណៈបក្ស នយោបាយថ្នាក់ជាតិរបស់គេ ហើយអាចនឹងមិនមែនជា បេក្ខជនដែលបានជាប់ឆ្នោតដោយឆ្នោតប្រជាប្រិយ នៅក្នុងការបោះឆ្នោតជាបឋមក្នុងរដ្ឋកាលីហ្វ័រនីញ៉ាឡើយ។

## រដ្ឋកាលីហ្វ័រនីញ៉ា បើកជាបឋម (ការិយាល័យអ្នកបោះឆ្នោត-បញ្ជូរឈ្មោះ)

- តំណែងនៅលើសន្លឹកឆ្នោត: ព្រឹទ្ធសភាសហរដ្ឋ, វិមានតំណាងរាស្ត្រសហរដ្ឋ, ការិយាល័យទូទាំងរដ្ឋ, និងការិយាល័យអង្គនីតិបញ្ញត្តិរដ្ឋ
- អ្នកណាអាចបោះឆ្នោតបាន: អ្នកបោះឆ្នោតណាមួយ អាចនឹងបោះឆ្នោតសំរាប់បេក្ខជនម្នាក់ ក្នុងការប្រកួតនិមួយៗ ទោះបើការប្រកាន់គណៈបក្សអ្វីក៏ដោយ។
- លទ្ធផល: បេក្ខជនកំពូល-ពីរនាក់ ទោះបើការប្រកាន់គណៈបក្សអ្វីក៏ដោយ ដែលបានសន្លឹកឆ្នោតច្រើនបំផុត ក្នុងការប្រកួតជាបឋមនិមួយៗ និងផ្លាស់ចូលទៅការបោះឆ្នោតទូទៅ។ បន្ទាប់ពីបោះឆ្នោតជាបឋម-កំពូលពីរដងមក ការបោះឆ្នោតទូទៅត្រូវតែបានប្រព្រឹត្តសូម្បីតែបើបេក្ខជនម្នាក់បានសន្លឹកឆ្នោតភាគច្រើន (យ៉ាងហោចបំផុត 50 ភាគរយ+1) និងសូម្បីតែបើមានបេក្ខជនតែម្នាក់ នៅក្នុងការបោះឆ្នោតជាបឋមក៏ដោយ។
- ប្រព័ន្ធបើកជាបឋមរបស់រដ្ឋកាលីហ្វ័រនីញ៉ា មិនអនុវត្តចំពោះបេក្ខជនដែលឈរឈ្មោះ សំរាប់ប្រធានាធិបតី ឬគណៈកម្មាធិការកណ្តាលនៃខោនធី ឬការិយាល័យតាមមូលដ្ឋានទេ។

ច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា តម្រូវឲ្យព័ត៌មាននៅខាងក្រោម បានផ្តិតនៅក្នុងការណែនាំនេះ។

## គណៈបក្ស-បញ្ជូរឈ្មោះ/ការិយាល័យនិន្នាការ

គណៈបក្សនយោបាយអាចនឹងបញ្ជូរឈ្មោះបេក្ខជនជាផ្លូវការ សំរាប់គណៈបក្ស-បញ្ជូរឈ្មោះ/ការិយាល័យនិន្នាការ នៅពេលបោះឆ្នោតជាបឋម។ បេក្ខជនដែលបានបញ្ជូរឈ្មោះ នឹងតំណាងឲ្យគណៈបក្សនោះ ជាបេក្ខជនផ្លូវការរបស់ខ្លួន សំរាប់ការិយាល័យជាក់លាក់នៅពេលបោះឆ្នោតទូទៅ ហើយសន្លឹកឆ្នោតនឹងឆ្លុះបញ្ចាំងចំណាត់តាំងជាផ្លូវការ។ អ្នកដែលបាន-សំឡេងឆ្នោតកំពូល សំរាប់គណៈបក្សនិមួយៗ នៅពេលការបោះឆ្នោតជាបឋម និងផ្លាស់ទៅការបោះឆ្នោតទូទៅ។ គណៈបក្ស ក៏ជ្រើសរើសមន្ត្រីនៃគណៈកម្មាធិការកណ្តាលនៃខោនធី នៅពេលបោះឆ្នោតជាបឋមដែរ។

អ្នកបោះឆ្នោត អាចបោះឆ្នោតតែនៅក្នុងការបោះឆ្នោតជាបឋមប៉ុណ្ណោះ នូវគណៈបក្សនយោបាយដែលគាត់បើកសំដែងការប្រកាន់គណៈបក្ស សំរាប់នៅពេលចុះឈ្មោះបោះឆ្នោត។ តែជាយ៉ាងណាមិញ គណៈបក្សនយោបាយ អាចនឹងអនុញ្ញាតឲ្យមនុស្សដែលបានបដិសេធបើកសំដែងការប្រកាន់គណៈបក្ស ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោត ជាបឋមរបស់គណៈបក្សនោះ។

## ការិយាល័យអ្នកបោះឆ្នោត-បញ្ជូរឈ្មោះ

គណៈបក្សនយោបាយគឺមិនមានសិទ្ធិ ដើម្បីបញ្ជូរឈ្មោះបេក្ខជនផ្លូវការ សំរាប់ការិយាល័យគណៈបក្ស-បញ្ជូរឈ្មោះ នៅពេលបោះឆ្នោតជាបឋមទេ។ បេក្ខជនដែលបានបញ្ជូរឈ្មោះ សំរាប់ការិយាល័យអ្នកបោះឆ្នោត-បញ្ជូរឈ្មោះ នៅពេលបោះឆ្នោតជាបឋម គឺជាអ្នកឈរឈ្មោះរបស់ប្រជាជន និងមិនមែនជាអ្នកឈរឈ្មោះជាផ្លូវការ របស់គណៈបក្សណាមួយ នៅពេលបោះឆ្នោតទូទៅទេ។ បេក្ខជនសំរាប់ការបញ្ជូរឈ្មោះ សំរាប់ការិយាល័យអ្នកបោះឆ្នោត-បញ្ជូរឈ្មោះ ត្រូវមានការប្រកាន់គណៈបក្សរបស់គាត់ ឬខ្វះនូវការប្រកាន់គណៈបក្ស ដែលបានថ្លែងនៅលើសន្លឹកឆ្នោត ប៉ុន្តែចំណាត់តាំងការប្រកាន់គណៈបក្ស ត្រូវបានជ្រើសរើសដោយបេក្ខជនប៉ុណ្ណោះ និងបានបង្ហាញជាព័ត៌មានសំរាប់អ្នកបោះឆ្នោតតែប៉ុណ្ណោះ។ វាមិនមែនមានន័យថាបេក្ខជន ត្រូវបានបញ្ជូរឈ្មោះ ឬបានយល់ព្រមដោយគណៈបក្សដែលបានចាត់តាំងឡើយ ឬថាមានសម្ព័ន្ធភាព រវាងគណៈបក្ស និងបេក្ខជន ហើយគ្មានបេក្ខជនដែលបានបញ្ជូរឈ្មោះដោយអ្នកបោះឆ្នោត ត្រូវបានចាត់ទុកជា បេក្ខជនបានបញ្ជូរឈ្មោះជាផ្លូវការ នៃគណៈបក្សនយោបាយណាមួយឡើយ។ នៅក្នុងកូនសៀវភៅគំរូសន្លឹកឆ្នោតរបស់ខោនធី គណៈបក្សអាចនឹងចុះរាយបេក្ខជន សំរាប់ការិយាល័យអ្នកបោះឆ្នោត-បញ្ជូរឈ្មោះ ដែលបានទទួលការយល់ព្រមជាផ្លូវការ ពីគណៈបក្ស។

អ្នកបោះឆ្នោតណាមួយ អាចនឹងបោះឆ្នោតសំរាប់បេក្ខជនណាម្នាក់ សំរាប់ការិយាល័យអ្នកបោះឆ្នោត-បញ្ជូរឈ្មោះ បើគេស្របតាម គុណសម្បត្តិផ្សេងៗទៀតដែលបានតម្រូវ ដើម្បីបោះឆ្នោតសំរាប់ការិយាល័យនោះ។ អ្នកបាន-សំឡេង ឆ្នោតកំពូលពីរនាក់ នៅពេលបោះឆ្នោតជាបឋម ផ្លាស់ទៅការបោះឆ្នោតទូទៅ សំរាប់ការិយាល័យអ្នកបោះឆ្នោត-បញ្ជូរ ឈ្មោះ សូម្បីតែបើបេក្ខជនទាំងពីរអ្នកមានចំណាត់តាំងការប្រកាន់គណៈបក្សដូចគ្នាក៏ដោយ។ គ្មានគណៈបក្សណាមានសិទ្ធិដើម្បីមានបេក្ខជន ដែលមានចំណាត់តាំងការប្រកាន់គណៈបក្សរបស់ខ្លួន ផ្លាស់ទៅការបោះឆ្នោតទូទៅឡើយ លុះត្រាតែបេក្ខជននោះជាមនុស្សម្នាក់នៃពីរនាក់ ដែលបាន-សំឡេងឆ្នោតខ្ពស់បំផុត នៅពេលបោះឆ្នោតជាបឋម។

## ការិយាល័យឥតនិន្នាការ

គណៈបក្សនយោបាយ ពុំមានសិទ្ធិដើម្បីបញ្ជូរឈ្មោះបេក្ខជន សំរាប់ការិយាល័យឥតនិន្នាការ នៅពេលបោះឆ្នោតជាបឋមឡើយ ហើយបេក្ខជននៅពេលបោះឆ្នោតជាបឋម គឺមិនមែនជាអ្នកឈរឈ្មោះជាផ្លូវការ នៃគណៈបក្សណាមួយ សំរាប់ការិយាល័យជាក់លាក់ នៅពេលបោះឆ្នោតទូទៅឡើយ។ បេក្ខជនសំរាប់ការបញ្ជូរឈ្មោះទៅការិយាល័យឥតនិន្នាការ មិនអាចនឹងចាត់តាំងការប្រកាន់គណៈបក្សរបស់គាត់ឡើយ ឬខ្វះនូវការប្រកាន់គណៈបក្សនៅលើសន្លឹកឆ្នោត។ អ្នកបាន-សំឡេងឆ្នោតកំពូលពីនាក់ នៅពេលបោះឆ្នោតជាបឋម ផ្លាស់ទៅការបោះឆ្នោតទូទៅ សំរាប់ការិយាល័យឥតនិន្នាការ។

---

# អ្នកបរិច្ចាគកំពូល ទៅបេក្ខជនទូទាំងរដ្ឋ និងវិធានការសន្លឹកឆ្នោត

TOP 10 $

នៅពេលគណៈកម្មាធិការមួយ (មនុស្សម្នាក់ ឬមនុស្សមួយក្រុម ដែលទទួល ឬចំណាយប្រាក់ សំរាប់គោលបំណងនៃការ បញ្ចុះបញ្ចូលអ្នកបោះឆ្នោត ដើម្បីគាំទ្រ ឬជំទាស់បេក្ខជន ឬវិធានការសន្លឹកឆ្នោត) គាំទ្រ ឬជំទាស់វិធានការសន្លឹកឆ្នោត ឬបេក្ខជន និងបានអង្គាសប្រាក់បានយ៉ាងតិចបំផុត $1 លាន គណៈកម្មាធិការនោះត្រូវតែរាយការណ៍ពីអ្នកបរិច្ចាគកំពូល 10 នាក់ ទៅ គណៈកម្មការអនុវត្តនយោបាយដោយយុត្តិធម៌ រដ្ឋកាលីហ្វ័រនីញ៉ា (California Fair Political Practices Commission, FPPC)។ គណៈកម្មាធិការត្រូវតែកែតម្រូវបញ្ជីអ្នកកំពូល 10 នាក់ នៅពេលណាមានការផ្លាស់ប្តូរ។

បញ្ជីទាំងនេះមាននៅលើវ៉ិបសៃត៍របស់ FPPC នៅ *http://www.fppc.ca.gov/transparency/top-contributors.html*។

# ជំនួយសំរាប់អ្នកបោះឆ្នោតដែលពិការ

ច្បាប់រដ្ឋ និងរដ្ឋបាលសហព័ន្ធ តម្រូវឲ្យកន្លែងបោះឆ្នោត មានលទ្ធភាពចេញចូលសំរាប់អ្នកបោះឆ្នោតដែលពិការ។ មន្ត្រីបោះឆ្នោតខោនធី ត្រួតពិនិត្យទីកន្លែងនិមួយៗ និងជាញឹកញាប់ ក៏ធ្វើការកែសំរួលជាបណ្ដោះអាសន្ន សំរាប់ថ្ងៃបោះឆ្នោត។ បុគ្គលគ្រប់ៗរូប ដែលធ្វើការនៅកន្លែងបោះឆ្នោត បានហ្វឹកហ្វឺនច្បាប់ការបោះឆ្នោត និងសិទ្ធិរបស់អ្នកបោះឆ្នោត រួមទាំងសេចក្ដីត្រូវការ ដើម្បីធ្វើការកែសំរួលសមហេតុផលនូវក្រឹត្យក្រម និងទំរង់ការ ដើម្បីអះអាងដល់លទ្ធភាពចេញចូលស្មើៗគ្នា។

ច្បាប់រដ្ឋ និងរដ្ឋបាលសហព័ន្ធ តម្រូវថាអ្នកបោះឆ្នោតទាំងអស់ អាចបោះឆ្នោតរបស់គេ ជាសំងាត់ និងដោយឯករាជ្យ។ កន្លែងបោះឆ្នោតនិមួយៗ យ៉ាងហោចបំផុតត្រូវតែមានម៉ាស៊ីនបោះឆ្នោតមួយ ដែលអនុញ្ញាតឲ្យអ្នកបោះឆ្នោតទាំងអស់ រួមទាំងជនពិការភ្នែក ឬអន់ភ្នែក ដើម្បីបោះឆ្នោតដោយគ្មានជំនួយ។ ម៉ាស៊ីនបោះឆ្នោត អនុញ្ញាតឲ្យអ្នកបោះឆ្នោតបញ្ជាក់ជំរើសរបស់គេ ហើយបើសិនមានខុសអ្វី វាអនុញ្ញាតឲ្យអ្នកបោះឆ្នោតកែជំរើសទាំងនោះ មុននឹងបញ្ជូនសន្លឹកឆ្នោតរបស់គេ។

## ឆែកមើលគំរូសន្លឹកឆ្នោតរបស់អ្នក

កូនសៀវភៅគំរូសន្លឹកឆ្នោតខោនធីរបស់អ្នក នឹង:

- រៀបរាប់ពីរបៀបជនដែលពិការអាចបោះឆ្នោតជាសំងាត់ និងដោយឯករាជ្យ
- តាំងសញ្ញារទេះកៅអី បើកន្លែងបោះឆ្នោតរបស់អ្នក មានលទ្ធភាពចេញចូលសំរាប់អ្នកបោះឆ្នោតដែលពិការ

## នៅឯកន្លែងបោះឆ្នោត

បើអ្នកត្រូវការជួយគូសសន្លឹកឆ្នោតរបស់អ្នក អ្នកអាចនឹងជ្រើសរើសមនុស្សដល់ទៅពីរនាក់ សំរាប់ឲ្យជួយអ្នក។ មនុស្សនេះមិនអាចជា:

- និយោជករបស់អ្នក ឬជនណាម្នាក់ដែលធ្វើការឲ្យនិយោជករបស់អ្នកឡើយ។
- អ្នកដឹកនាំសហជីពការងាររបស់អ្នក ឬជនណាម្នាក់ដែលធ្វើការឲ្យសហជីពការងាររបស់អ្នកឡើយ។

*ការបោះឆ្នោតតាមចិញ្ចើមថ្នល់* អនុញ្ញាតឲ្យអ្នកចតរថយន្តយ៉ាងជិតបំផុត ទៅនឹងកន្លែងបោះឆ្នោតរបស់អ្នក។ មន្ត្រីបោះឆ្នោតនឹងនាំឲ្យអ្នកចុះហត្ថលេខាបញ្ជីឈ្មោះ សន្លឹកឆ្នោត និងសំភារៈបោះឆ្នោតអ្វីមួយផ្សេងទៀត ដែលអ្នកអាចនឹងត្រូវការ ទោះបើតាមពិតអ្នកនៅនឹងចិញ្ចើមថ្នល់ ឬនៅក្នុងរថយន្ត។

សូមទាក់ទងការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ក្រែងលោបើមានការបោះឆ្នោតតាមចិញ្ចើមថ្នល់ នៅឯកន្លែងបោះឆ្នោតរបស់អ្នក។

# ព័ត៌មានណែនាំអ្នកបោះឆ្នោតរដ្ឋ ទល់នឹង កូនសៀវភៅគំរូសន្លឹកឆ្នោតខោនធី

ឋានៈជាអ្នកបោះឆ្នោតបានចុះឈ្មោះ អ្នកនឹងទទួលធនធានព័ត៌មាន *ពីរ* បែប តាមប្រៃសណីយ៍:

**ព័ត៌មានណែនាំអ្នកបោះឆ្នោតរដ្ឋ *(ការណែនាំនេះ)***

**មាន**ព័ត៌មាន អំពីបេក្ខជនរដ្ឋបាលសហព័ន្ធ និងសំណើទូទាំងរដ្ឋ។

**ព័ត៌មានបេក្ខជន:**
ប្រធានាធិបតី (តាមអ៊ិនធឺណិតនៅ *www.voterguide.sos.ca.gov*)
ព្រឹទ្ធសភាសហរដ្ឋអាមេរិក

**សំណើរបស់រដ្ឋ:**
សំណើ 50

**កូនសៀវភៅគំរូសន្លឹកឆ្នោតខោនធីរបស់អ្នក**

**មាន**គំរូសន្លឹកឆ្នោតរបស់អ្នក និងព័ត៌មានអំពីបេក្ខជនតាមមូលដ្ឋាន វិធានការសន្លឹកឆ្នោត និងទីកន្លែងនៃកន្លែងបោះឆ្នោតរបស់អ្នក។

**ព័ត៌មានបេក្ខជន:**
តំណាងរាស្ត្រសហរដ្ឋអាមេរិកក្នុងសភា
ព្រឹទ្ធសភារដ្ឋ
សមាជិករដ្ឋសភា
ការិយាល័យតាមមូលដ្ឋានផ្សេងទៀត

**វិធានការសន្លឹកឆ្នោតតាមមូលដ្ឋាន:**
ខុសៗគ្នាតាមខោនធី

# ការបោះឆ្នោតបណ្ដោះអាសន្ន

បើសិនឈ្មោះរបស់អ្នក ពុំមាននៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅឯកន្លែងបោះឆ្នោតរបស់អ្នកទេ ក៏អ្នកមានសិទ្ធិដើម្បីបោះឆ្នោត នូវសន្លឹកឆ្នោតបណ្ដោះអាសន្នដែរ។

## តើសន្លឹកឆ្នោតបណ្ដោះអាសន្ន ជាអ្វី?

សន្លឹកឆ្នោតបណ្ដោះអាសន្ន គឺជាសន្លឹកឆ្នោតធម្មតា ដែលបានដាក់ក្នុងស្រោមសំបុត្រពិសេស មុននឹងត្រូវបានដាក់ទៅក្នុងហិបឆ្នោត។

## តើអ្នកណាអាចបោះ សន្លឹកឆ្នោតបណ្ដោះអាសន្នបាន?

សន្លឹកឆ្នោតបណ្ដោះអាសន្ន គឺជាសន្លឹកឆ្នោតបោះដោយអ្នកបោះឆ្នោតដែលៈ

- បានជឿថាគេបានចុះឈ្មោះបោះឆ្នោត ទោះបើឈ្មោះរបស់គេពុំមាននៅលើបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតជាផ្លូវការ នៅឯកន្លែងបោះឆ្នោត។
- បោះឆ្នោតតាមប្រៃសណីយ៍ ប៉ុន្តែមិនបានទទួលសន្លឹកឆ្នោតរបស់គេ ឬពុំមានសន្លឹកឆ្នោតរបស់គេមកជាប់ខ្លួនគេ ហើយបែរជាចង់បោះឆ្នោត នៅឯកន្លែងបោះឆ្នោត។

## តើមានអ្វីកើតឡើង បន្ទាប់ពីអ្នកបោះសន្លឹកឆ្នោតបណ្ដោះអាសន្ន?

សន្លឹកឆ្នោតបណ្ដោះអាសន្ន នឹងបានរាប់បន្ទាប់ពីមន្ត្រីបោះឆ្នោតបានបញ្ជាក់ ថាអ្នកបានចុះឈ្មោះបោះឆ្នោតនៅក្នុងខោនធីនោះ ហើយអ្នកមិនទាន់ បានបោះឆ្នោត ក្នុងការបោះឆ្នោតនោះនៅឡើយទេ។

អ្នកអាចនឹងបោះសន្លឹកឆ្នោតបណ្ដោះអាសន្ន នៅឯកន្លែងបោះឆ្នោតណាមួយ នៅក្នុងខោនធីដែលអ្នកបានចុះឈ្មោះបោះឆ្នោត តែជាយ៉ាងណាមិញ ដរាបតែការបោះឆ្នោតជំទាស់ថាអ្នកមានសិទ្ធិដើម្បីបោះឆ្នោត សំរាប់នឹងបានរាប់។

## តើអ្នកអាចឆែកមើលស្ថានភាព នៃសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នក ដោយដូចម្ដេច?

អ្នកបោះឆ្នោតគ្រប់ៗរូប ដែលបានបោះសន្លឹកឆ្នោតបណ្ដោះអាសន្ន សុទ្ធតែមានសិទ្ធិសាកសួរឲ្យដឹង ពីមន្ត្រីបោះឆ្នោតខោនធីរបស់គេ បើសិនគេមិនបានរាប់សន្លឹកឆ្នោត ហើយបើមិនបានរាប់ទេ តើមូលហេតុអ្វីមិនបានរាប់វា។

មើល *http://www.sos.ca.gov/elections/ballot-status* សំរាប់បញ្ជីឈ្មោះខោនធី ដើម្បីទាក់ទង និងព័ត៌មានស្ដីពីរបៀបឆែកមើលស្ថានភាព នៃសន្លឹកឆ្នោតបណ្ដោះអាសន្នរបស់អ្នក។

# ព័ត៌មានថ្ងៃបោះឆ្នោត

**កន្លែងបោះឆ្នោត បើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ នៅថ្ងៃអង្គារ ទី 7 ខែមិថុនា។ បើអ្នកឈរក្នុងជួរមុនម៉ោង 8:00 យប់ អ្នកនៅតែអាច បោះឆ្នោតបាន។**

មធ្យោបាយ 4 យ៉ាង ដើម្បីរកកន្លែងបោះឆ្នោតរបស់អ្នកៈ

- ឆែកមើលក្របខាងក្រោយនៃកូនសៀវភៅគំរូសន្លឹកឆ្នោត ដែលមន្ត្រីបោះឆ្នោតខោនធីរបស់អ្នក បានផ្ញើទៅឲ្យអ្នក។
- ហៅលេខ (888) 345-4917
- តាមអ៊ិនទ័រណិតនៅ *www.sos.ca.gov/elections/polling-place*
- វាយពាក្យ *Vote* ទៅលេខ GOVOTE (468683)

# ការិយាល័យបោះឆ្នោតខោនធី

**Alameda County**
(510) 272-6973
*www.acgov.org/rov*

**Alpine County**
(530) 694-2281
*www.alpinecountyca.gov*

**Amador County**
(209) 223-6465
*www.co.amador.ca.us/government/elections*

**Butte County**
(530) 538-7761 ឬ
(800) 894-7761 (បិតក្នុងខោនធី Butte)
*http://buttevotes.net*

**Calaveras County**
(209) 754-6376 ឬ (209) 754-6375
*www.elections.calaverasgov.us/elections.aspx*

**Colusa County**
(530) 458-0500 ឬ (877) 458-0501
*www.countyofcolusa.org/elections*

**Contra Costa County**
(925) 335-7800
*www.cocovote.us*

**Del Norte County**
(707) 464-7216 ឬ (707) 465-0383
*www.co.del-norte.ca.us*

**El Dorado County**
(530) 621-7480 ឬ (800) 730-4322
*www.edcgov.us/elections*

**Fresno County**
(559) 600-8683
*www.co.fresno.ca.us/elections*

**Glenn County**
(530) 934-6414
*www.countyofglenn.net/elections*

**Humboldt County**
(707) 445-7481
*humboldtgov.org/elections*

**Imperial County**
(442) 265-1074
*www.co.imperial.ca.us*

**Inyo County**
(760) 878-0224
*elections.inyocounty.us*

**Kern County**
(661) 868-3590
*www.co.kern.ca.us/elections*

**Kings County**
(559) 852-4890
*www.countyofkings.com*

**Lake County**
(707) 263-2372
*www.co.lake.ca.us/government/directory/rov.htm*

**Lassen County**
(530) 251-8217 ឬ (530) 251-8352
*http://www.lassencounty.org*

**Los Angeles County**
(800) 815-2666 ជំរើស 2 ឬ
(562) 466-1323
*www.lavote.net*

**Madera County**
(559) 675-7720
*www.madera-county.com*

**Marin County**
(415) 473-6456
*www.marinvotes.org*

**Mariposa County**
(209) 966-2007
*www.mariposacounty.org*

**Mendocino County**
(707) 234-6819
*www.co.mendocino.ca.us/acr/elections*

**Merced County**
(209) 385-7541 ឬ (800) 561-0619
*www.mercedelections.org*

**Modoc County**
(530) 233-6205
*www.co.modoc.ca.us*

**Mono County**
(760) 932-5537 ឬ (760) 932-5530
*www.monocounty.ca.gov/elections*

**Monterey County**
(831) 796-1499 ឬ (866) 887-9274
*www.montereycountyelections.us/*

**Napa County**
(707) 253-4321 ឬ (707) 253-4374
*www.countyofnapa.org*

**Nevada County**
(530) 265-7115
*www.mynevadacounty.com/nc/elections/Pages/Home.aspx*

**Orange County**
(714) 567-7600
*www.ocvote.com*

**Placer County**
(530) 886-5650
*www.placerelections.com*

**Plumas County**
(530) 283-6256 ឬ (844) 676-8683
*www.countyofplumas.com*

**Riverside County**
(951) 486-7200 ឬ (800) 773-8683
*www.voteinfo.net*

**Sacramento County**
(916) 875-6451 ឬ (800) 762-8019
*www.elections.saccounty.net*

**San Benito County**
(831) 636-4016 ឬ (831) 636-4017
*www.sbcvote.us*

**San Bernardino County**
(909) 387-8300 ឬ (800) 881-8683
*www.sbcountyelections.com*

**San Diego County**
(858) 565-5800
*www.sdvote.com*

**San Francisco County**
(415) 554-4375
*www.sfelections.org*

**San Joaquin County**
(209) 468-2890
*www.sjcrov.org*

**San Luis Obispo County**
(805) 781-5228 ឬ (805) 781-5080
*www.slovote.com*

**San Mateo County**
(650) 312-5222
*www.shapethefuture.org*

**Santa Barbara County**
(805) 568-2200 ឬ (800) 722-8683
*www.sbcvote.com*

**Santa Clara County**
(408) 299-8683 ឬ (866) 430-8683
*www.sccvote.org*

**Santa Cruz County**
(831) 454-2060
*www.votescount.com*

**Shasta County**
(530) 225-5730
*www.co.shasta.ca.us*

**Sierra County**
(530) 289-3295
*www.sierracounty.ca.gov*

**Siskiyou County**
(530) 842-8084
*www.sisqvotes.org*

**Solano County**
(707) 784-6675
*www.solanocounty.com/elections*

**Sonoma County**
(707) 565-6800 ឬ (800) 750-VOTE
*vote.sonoma-county.org*

**Stanislaus County**
(209) 525-5200 ឬ (209) 525-5201
*www.stanvote.com*

**Sutter County**
(530) 822-7122 ឬ (530) 713-3226
*www.suttercounty.org/elections*

**Tehama County**
(530) 527-8190
*www.co.tehama.ca.us*

**Trinity County**
(530) 623-1220
*www.trinitycounty.org*

**Tulare County**
(559) 624-7300
*http://www.tularecounty.ca.gov/registrarofvoters/*

**Tuolumne County**
(209) 533-5570
*www.co.tuolumne.ca.us/elections*

**Ventura County**
(805) 654-2664
*venturavote.org*

**Yolo County**
(530) 666-8133 ឬ (800) 649-9943
*www.yoloelections.org*

**Yuba County**
(530) 749-7855
*www.yubaelections.org*

# ព័ត៌មានណែនាំអ្នកបោះឆ្នោត អំពីសំឡេង និងអក្សរពុម្ពធំៗ

ការណែនាំនេះមានដោយឥតអស់ថ្លៃ ជាភាសា អង់គ្លេស, ចិន, ហិណ្ឌូ, ជប៉ុន, ខ្មែរ, កូរ៉េ, អេស្ប៉ាញ៉ុល, តាហ្គាឡុក, ថៃ, និងវៀតណាម។

ដើម្បីស្នើសុំ:

✆ ទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោត របស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃ (888) 345-4917

💻 មើល *www.sos.ca.gov*

🌐 ទាញយកសំឡេងជាកំណែ MP3 នៅ *www.voterguide.sos.ca.gov/km/audio*

# ការចុះឈ្មោះអ្នកបោះឆ្នោត

បើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ អ្នកមិនបាច់ចុះឈ្មោះទៀតទេ ***លុះត្រាតែ*** អ្នកដូរឈ្មោះ អាសយដ្ឋានផ្ទះ អាសយដ្ឋានផ្ញើសំបុត្ររបស់អ្នក ឬបើអ្នកចង់ដូរ ឬជ្រើសរើស គណៈបក្សនយោបាយមួយ។

អ្នកអាចចុះឈ្មោះបោះឆ្នោត តាមអ៊ិនធឺណិតនៅ *RegisterToVote.ca.gov*។ ឬទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោត របស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃ (888) 345-4917 ដើម្បីឲ្យគេផ្ញើក្រដាសបំពេញទៅឲ្យអ្នក។

ក្រដាសបំពេញចុះឈ្មោះអ្នកបោះឆ្នោត អាចរកឃើញនៅតាមការិយាល័យប្រៃសណីយ៍ បណ្ណាល័យភាគច្រើន ទាំងនៅតាមការិយាល័យរដ្ឋាភិបាលទីក្រុង និងខោនធី នៅតាមការិយាល័យបោះឆ្នោតខោនធី និងនៅតាមការិយាល័យរបស់រដ្ឋលេខាធិការ រដ្ឋកាលីហ្វ័រនីញ៉ា។

# ព័ត៌មានភាពឯកជន ការចុះឈ្មោះអ្នកបោះឆ្នោត

**កម្មវិធី Safe at Home ការចុះឈ្មោះអ្នកបោះឆ្នោតជាសំងាត់ (Safe at Home Confidential Voter Registration Program):** អ្នកបោះឆ្នោតខ្លះកំពុងតែប្រឈមមុខនឹងស្ថានការណ៍នៃ ការគំរាមកំហែងជីវិត (ដូចជា អំពើហិង្សាក្នុង គ្រួសារ, ការឈ្លបចាប់ជនរងគ្រោះ) អាចនឹងមានសិទ្ធិទទួលស្ថានភាព អ្នកបោះឆ្នោតជាសំងាត់។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងកម្មវិធី Safe at Home របស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃ (877) 322-5227 ឬមើល *http://www.sos.ca.gov/registries/safe-home*។

**ព័ត៌មានភាពឯកជនអ្នកបោះឆ្នោត:** ព័ត៌មាននៅលើលិខិតសច្ចា ការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក នឹងបានប្រើដោយ មន្ត្រីបោះឆ្នោតដើម្បីផ្ញើព័ត៌មានជាផ្លូវការទៅឲ្យអ្នក ស្តីពីវិធីការបោះឆ្នោត ដូចជាទីកន្លែងនៃកន្លែងបោះឆ្នោតរបស់អ្នក ព្រមទាំងរឿងរ៉ាវនានា និងបេក្ខជនដែលនឹងមានឈ្មោះនៅលើសន្លឹកឆ្នោត។ ការប្រើប្រាស់ជាពាណិជ្ជកម្ម នូវព័ត៌មានការចុះឈ្មោះអ្នកបោះឆ្នោត ត្រូវបានហាមផ្តាច់ដោយច្បាប់ និងជាបទល្មើសជាមជ្ឈិម។ ព័ត៌មានអ្នកបោះឆ្នោត អាចនឹងបានផ្តល់ទៅឲ្យបេក្ខជន សំរាប់គោលបំណងនៃការិយាល័យគណៈកម្មាធិការវិធានការសន្លឹកឆ្នោត ឬមនុស្សផ្សេងៗទៀត សំរាប់ការបោះឆ្នោត ខាងការសិក្សា ខាងសារព័ត៌មាន នយោបាយ ឬរដ្ឋាភិបាល ដូចបានសំរេចដោយរដ្ឋលេខាធិការ។ សំបុត្របើកបររថយន្ត និងលេខសូស្យាល់សិគ្យួរិទី ឬហត្ថលេខារបស់អ្នក ដូចបានបង្ហាញនៅលើប័ណ្ណការចុះឈ្មោះ របស់អ្នក មិនអាចបានបញ្ចេញសំរាប់គោលបំណងទាំងនេះ បានឡើយ។ បើអ្នកមានសំណួរអ្វីអំពីការប្រើប្រាស់ នូវព័ត៌មានអ្នកបោះឆ្នោត ឬចង់រាយការណ៍សេចក្តីសង្ស័យពីការប្រើប្រាស់ខុសឆ្គង នូវព័ត៌មានបែបទាំងនោះ សូមទាក់ទងលេខពិសេស អ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមលេខ (888) 345-4917។

# កាលបរិច្ឆេទ ត្រូវនឹកចាំ!



## ត្រូវនឹកចាំទៅបោះឆ្នោត!

កន្លែងបោះឆ្នោត បើកពីម៉ោង 7:00 ព្រឹក ដល់ 8:00 យប់ នៅថ្ងៃបោះឆ្នោត!

### ខែឧសភា

| អា | ច | អ | ព | ព្រ | សុ | ស |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8 | 9 | 10 | 11 | 12 | 13 | 14 |
| 15 | 16 | 17 | 18 | 19 | 20 | 21 |
| 22 | 23 | 24 | 25 | 26 | 27 | 28 |
| 29 | 30 | 31 | | | | |

**ថ្ងៃទី 9 ខែឧសភា 2016**

ថ្ងៃដំបូងដើម្បីបោះឆ្នោត-តាម-សំបុត្រ។

**ថ្ងៃទី 23 ខែឧសភា 2016**

ថ្ងៃចុងក្រោយ ដើម្បីចុះឈ្មោះបោះឆ្នោត។

**ថ្ងៃទី 31 ខែឧសភា 2016**

ថ្ងៃចុងក្រោយ ដែលមន្ត្រីបោះឆ្នោតខោនធី នឹងទទួលយកពាក្យសុំរបស់អ្នកបោះឆ្នោត ណាម្នាក់ សំរាប់សន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ។

---

### ខែមិថុនា

| អា | ច | អ | ព | ព្រ | សុ | ស |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 |
| 12 | 13 | 14 | 15 | 16 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 | 25 |
| 26 | 27 | 28 | 29 | 30 | | |

**ថ្ងៃទី 7 ខែមិថុនា 2016**

**ថ្ងៃបោះឆ្នោត!**